## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង
# រវាង
# ក្រុមហ៊ុន ហប ឡុក (ខេមបូឌា) ឯ.ក
# ជាមួយតំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន

នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៤ វេលាម៉ោង០៨ និង០០នាទី ព្រឹក នៅក្នុងរោងចក្រ **ហប ឡុក (ខេមបូឌា) ឯ.ក** មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន នឹងតំណាងកម្មករ និយោជិត ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករ និយោជិតទាំងអស់ស្តីពីស្ថានភាព បច្ចុប្បន្ននៃក្រុមហ៊ុនដែលគ្មានការបញ្ជាទិញដែលបណ្តាលឲ្យសង្វាក់ផលិតកម្មត្រូវផ្អាកដំណើរការ ។ ហេតុដូចនេះ ក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតចំនួន ២៣៦នាក់(ស្រី១៦៥នាក់) រយៈពេល ៩ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ដល់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៤ ។ ហើយក្នុងកំឡុងពេលព្យួរការងារនេះ កម្មករ និយោជិត បានឯកភាពទទួលការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួល ១៥ដុល្លាសហរដ្ឋអាមេរិចក្នុងរយៈពេល ៩ថ្ងៃ ៕

ក្រុមហ៊ុនឯកភាពបើកប្រាក់ឧបត្ថម្ភជូននៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៤។

អង្គប្រជុំបានចប់នៅវេលាម៉ោង០៨ និង ៣០នាទី ព្រឹក នាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីក រាយ និងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោយល់សហការគ្នាយ៉ាងរលូន ។

ថ្ងៃស្រុក ១០ រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨
កណ្តាល ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤

**តំណាងក្រុមហ៊ុន**

**ស្នាមមេដៃតំណាងកម្មករ និយោជិត**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ម្ចាស់ ឬនាយកក្រុមហ៊ុនៈ ហប ឡុក (ខេមបូឌា) ឯ.ក**
លេខបញ្ជីពាណិជ្ជកម្មៈ ០០០៣៨២១៧
លេខអត្តសញ្ញាណសហគ្រាសក្នុង ប.ស.ស.៖ ១០១៣៧១៩៨
លេខគណនីធនាគារៈ ៣៤៤១-០៣៤១៨៧៧៤-១-៤ (ACLEDA)
អាសយដ្ឋានៈ ភូមិ ត្រពាំងប្រុយ ឃុំ/សង្កាត់ បែកចាន ក្រុង/ស្រុក/ខណ្ឌ អង្គស្នួល រាជធានី/ខេត្ត កណ្ដាល
ទូរស័ព្ទលេខៈ ០៧០៩៧៥៨៥៦ អ៊ីមែល (E-mail)៖ Lin.shiming2017@gmail.com

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**តាមរយៈ** ៖ លោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល
**កម្មវត្ថុ** ៖ សំណើសុំព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតចំនួន ១៦០នាក់ រយៈពេល ៩ថ្ងៃ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តមរដ្ឋមន្ត្រី មេត្តាជ្រាបថា ដោយមូលហេតុក្រុមហ៊ុនយើងខ្ញុំ គ្មានការបញ្ជាទិញដែលបណ្តាលឲ្យសង្វាក់ផលិតកម្មត្រូវផ្អាកដំណើរការ ដូច្នេះក្រុមហ៊ុនយើងខ្ញុំស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ២៣៦នាក់ (ស្រី ១៦៥នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៧២៣នាក់ (ស្រី ៤៧៨នាក់) រយៈពេល ៩ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៤។

ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតចំនួន ១៥ដុល្លារអាមេរិក។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម ឯកឧត្តមរដ្ឋមន្ត្រី មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

កណ្តាល ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤
ហត្ថលេខា និងត្រា
ម្ចាស់ ឬនាយក

ក្រុមហ៊ុនហបឡុក (ខេមបូឌា) ឯ.ក
រដ្ឋបាល
HR
HOP LOK (CAMBODIA) CO.,LTD

សូមភ្ជាប់មកជាមួយៈ
- កិច្ចព្រមព្រៀងអំពីនីតិវិធីទូទាត់ជាមួយកម្មករនិយោជិតចំនួន ៣ច្បាប់
- បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារចំនួន ៣ច្បាប់ និងជា Soft Copy (Ms Excel) ទៅ E-mail: suspension@nea.gov.kh
- បញ្ជីបើកប្រាក់ឈ្នួលចុងក្រោយមុនពេលស្នើសុំព្យួរកិច្ចសន្យាការងារ
- វិញ្ញាបនបត្រពាណិជ្ជកម្ម (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់
- ប័ណ្ណពន្ធប៉ាតង់ (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់
- អាជ្ញាប័ណ្ណទេសចរណ៍ (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់ (វិស័យទេសចរណ៍)
- វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន ក្នុង ប.ស.ស. ចំនួន ៣ច្បាប់ (បើមាន)